រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

# សេចក្តីជូនដំណឹងលេខ ១៥៦ សហវ ស្តីពីការកំណត់ទូទាត់ថ្លៃឈ្នួល ប្រើប្រាស់បរិធានទូរស័ព្ទចល័ត

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## សូមជំរាបជូន

ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងគ្រប់ស្ថាប័នកណ្តាល

ឯកឧត្តម អភិបាលគ្រប់ខេត្ត - ក្រុង

**កម្មវត្ថុ :** ស្តីពីការកំណត់ទូទាត់ថ្លៃឈ្នួលប្រើប្រាស់បរិធានទូរស័ព្ទចល័ត ។

**យោង :** -សេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ៣៤៣ សហវ ចុះថ្ងៃទី ០៧ ខែ កញ្ញា ១៩៩៣

-កិច្ចពិភាក្សារបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១.៣៥១ សជណ.ពាហ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៤

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមរដ្ឋមន្ត្រី -រដ្ឋលេខាធិការ -អភិបាល ខេត្ត -ក្រុងថា ÷ ចាប់ពីខែកញ្ញា ឆ្នាំ ១៩៩៣ មកដល់បច្ចុប្បន្ននេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសំរួលទូទាត់ថ្លៃ ឈ្នួលប្រើប្រាស់ទូរស័ព្ទក្នុងការទំនាក់ទំនងក្នុង ប្រទេស និងក្រៅប្រទេសជូនដល់ក្រសួង និងអង្គភាពមួយចំនួនដ៏វិញ ស្ថាប័នកណ្តាល និងជុំវិញខេត្ត- ក្រុង ចំពោះ បរិធានទូរស័ព្ទដែលស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួង ឬអង្គភាពខេត្ត- ក្រុង តាមកំរិតកំណត់ នៃសេចក្តីជូនដំណឹង ដូចយោងខាងលើជាទៀងរាល់ខែ ។

ក្នុងដំណើរការអនុវត្តតាមកំរិតកំណត់នៃការប្រើប្រាស់ទូរស័ព្ទកន្លងមកនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបាន សង្កេតឃើញថា កំរិតថ្លៃឈ្នួលប្រើប្រាស់បរិធានទូរស័ព្ទកំពុងស្ថិតក្នុងស្ថានភាពខ្ជះខ្ជាយដែលធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ ធ្ងរដល់ការចំណាយថវិការដ្ឋដែលកំពុងជួបការលំបាក ។

តាមហេតុផលខាងលើនេះ និងដើម្បីទប់ស្កាត់ការខ្ជះខ្ជាយខាងលើនេះ ក៏ដូចជាការអនុវត្តន៍ ការសន្សំសំចៃអោយបានជាអតិបរិមាផង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកំណត់សារ ជាថ្មីឡើងវិញនូវថ្លៃឈ្នួលប្រើប្រាស់ បរិធានទូរស័ព្ទចល័ត ដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌត្រឹមត្រូវ របស់ក្រសួង ឬស្ថាប័ន និងអង្គភាពដោយអនុញ្ញាតអោយទូទាត់ ចំពោះតែការទំនាក់ទំនងក្នុងប្រទេស លើកលែងតែសម្តេច នាយករដ្ឋមន្ត្រីទាំងពីរប៉ុណ្ណោះតាមកំរិតកំណត់ដូចតទៅនេះ ÷

ពោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ត្រូវបានកំនត់អោយទូទាត់ថ្លៃ ប្រើប្រាស់ក្នុងទូរស័ព្ទមួយគ្រឿងមិនអោយលើសពី១៥០ ដុល្លារអាមេរិកក្នុងមួយខែគិតទាំងប្រាក់កក់ ២៥ ដុល្លារអាមេរិកផង ។

២_ចំពោះព្រះអង្គម្ចាស់ ឯកឧត្តមថ្នាក់ទេសរដ្ឋមន្ត្រី_រដ្ឋមន្ត្រី ត្រូវបានកំណត់អោយទូទាត់ថ្លៃប្រើប្រាស់ក្នុងទូរស័ព្ទមួយគ្រឿងមិនអោយលើសពី ១២៥ ដុល្លារអាមេរិកក្នុងមួយខែគិតទាំងប្រាក់កក់២៥ ដុល្លារអាមេរិកផង។

៣_ចំពោះព្រះអង្គម្ចាស់ ឯកឧត្តម ថ្នាក់រដ្ឋលេខាធិការ_អនុរដ្ឋលេខាធិការ និងអភិបាលខេត្ត_ក្រុងត្រូវបានកំណត់អោយទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទមួយគ្រឿងមិនអោយលើសពី ១០០ ដុល្លារអាមេរិក ក្នុងមួយខែ គិតទាំងប្រាក់កក់ ២៥ ដុល្លារ អាមេរិកផង ។

៤_ចំពោះព្រះអង្គម្ចាស់ អស់លោក លោកស្រី ចាប់ពីថ្នាក់អគ្គនាយក_អភិបាលរងខេត្ត_ក្រុងចុះក្រោមត្រូវបាន កំណត់អោយទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទមួយគ្រឿងមិនអោយលើសពី ៧៥ ដុល្លារអាមេរិក ក្នុងមួយខែ គិតទាំងប្រាក់កក់ ២៥ ដុល្លារអាមេរិកផង ។

ប៉ុន្តែ ក្នុងករណីមានទំនាក់ទំនងក្នុងការងាររាជការទៅក្រៅប្រទេស ព្រះអង្គម្ចាស់ ឯកឧត្តម អស់លោក លោកស្រី ដូចក្នុងចំណុចទាំងបួនខាងលើ ត្រូវប្រើប្រាស់ទំនាក់ទំនងតាមទូរសារ ( FAX ) ឬ តាមទូរស័ព្ទ (IDD) របស់ក្រសួង ឬ អង្គភាព ដោយឆ្លងតាមលោកនាយកខុទ្ទកាល័យក្រសួង ឬ ខេត្ត-ក្រុង ។

ការកំណត់ថ្មីនៃការទូទាត់ថ្លៃឈ្នួលប្រើប្រាស់បរិធានទូរស័ព្ទចល័តនេះ នឹងត្រូវអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៤ តទៅ ហើយខ្លឹមសារពីមុនដែលផ្ទុយពីការកំណត់នេះ ត្រូវចាត់ទុកជា និរាករណ៍ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត-ក្រុងទាំងអស់ មានវិធានការអោយអនុវត្ត នូវការកំណត់ខាងលើនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា ៦... ...៣

**គាត ឈន់**

***